13.05.25

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

លេខ....០៣៧......អ. ស. ហ.ប្រក

# ប្រកាស
# ស្តីពី
# ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មការបច្ចេកទេស សម្រាប់ការរាយការណ៍ព័ត៌មានចីរភាព

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ



#១៦៨F ផ្លូវលេខ ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
#168F, St. 598, Chrang Chamres 1, Russei Keo, Phnom Penh
Website: fsa.gov.kh, Telegram: t.me/fsacambodia
ទូរស័ព្ទ: (+៨៥៥) ២៣ ៩៩០ ៧០០
Phone: (+855) 23 990 700
info@fsa.gov.kh

- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- យោងតាមសំណូមពរចាំបាច់នៃការងារ

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើត **គណៈកម្មការបច្ចេកទេសសម្រាប់ការរាយការណ៍ព័ត៌មានចីរភាព** ហៅកាត់ថា **គ.រ.ច.** ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- | អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម | ប្រធាន |
| ២- | អគ្គនាយករងនៃនិយ័តករគណនេយ្យនិងសវនកម្ម ១រូប | អនុប្រធាន |
| ៣- | តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ១រូប | សមាជិក |
| ៤- | តំណាងក្រសួងផែនការ ១រូប | សមាជិក |
| ៥- | តំណាងក្រសួងបរិស្ថាន ១រូប | សមាជិក |
| ៦- | តំណាងធនាគារជាតិនៃកម្ពុជា ១រូប | សមាជិក |
| ៧- | តំណាងនិយ័តករមូលបត្រកម្ពុជា ១រូប | សមាជិក |
| ៨- | តំណាងនិយ័តករធានារ៉ាប់រងកម្ពុជា ១រូប | សមាជិក |
| ៩- | តំណាងវិទ្យាស្ថានជាតិស្ថិតិ ១រូប | សមាជិក |
| ១០- | តំណាងនិយ័តករគណនេយ្យនិងសវនកម្ម ១រូប | សមាជិក |
| ១១- | តំណាងក្រុមហ៊ុនគណនេយ្យ និង/ឬ សវនកម្ម ជាសមាជិកសកម្មរបស់ វ.គ.ស.ក. ៥រូប | សមាជិក។ |

**ប្រការ២.-**

សមាសភាពជាក់ស្ដែងរបស់ **គ.រ.ច.** ដែលជាតំណាងមកពីក្រសួង ស្ថាប័ន និងអង្គភាព ដូចមានចែងក្នុងប្រការ១ នៃប្រកាសនេះ ត្រូវតែងតាំង ផ្លាស់ប្ដូរ និងបញ្ចប់តួនាទីភារកិច្ចដោយសេចក្ដីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ផ្អែកតាមសំណើរបស់ប្រធានក្រសួង ស្ថាប័ន និងអង្គភាពសាមី។

សមាសភាពដែលជាតំណាងមកពីក្រសួង ស្ថាប័ន និងអង្គភាពដូចមានចែងក្នុងប្រការ១ នៃប្រកាសនេះ ត្រូវតែជាអ្នកបច្ចេកទេស ដែលមានចំណេះជំនាញពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ **គ.រ.ច.**។

**ប្រការ៣.-**

**គ.រ.ច.** អាចអញ្ជើញអ្នកជំនាញ និងភាគីពាក់ព័ន្ធ ដើម្បីចូលរួមផ្ដល់យោបល់តាមការចាំបាច់។ អ្នកជំនាញ និងភាគីពាក់ព័ន្ធទាំងនេះ ទទួលបានប្រាក់លាភការដូចសមាជិក។

**គ.រ.ច.** អាចប្រើប្រាស់ត្រារបស់និយ័តករគណនេយ្យនិងសវនកម្ម ដើម្បីបំពេញមុខងារភារកិច្ចរបស់ខ្លួន។

**ប្រការ៤.-**

**គ.រ.ច.** មានមុខងារភារកិច្ចដូចតទៅ៖

- អនុម័តលើសេចក្ដីព្រាងផែនការ គោលការណ៍ និងវិធានការ ពាក់ព័ន្ធទៅនឹងការរាយការណ៍ព័ត៌មានចីរភាព និងដាក់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងសម្រេច



8ʌ
V

- ផ្តល់យោបល់លើការអនុវត្តស្តង់ដារាយការណ៍ព័ត៌មានចីរភាពជូន **ន.គ.ស.**
- ផ្តល់យន្តការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការគាំទ្រដល់ការអនុវត្តការរាយការណ៍ព័ត៌មានចីរភាព តាមក្រសួង-ស្ថាប័ន និងអង្គភាព ព្រមទាំងស្ថាប័នតំបន់ និងអន្តរជាតិ
- អនុម័តនិងបច្ចុប្បន្នភាពផែនទីបង្ហាញផ្លូវ និងផែនការសកម្មភាពលម្អិតរបស់ **គ.រ.ច.**
- ពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តផែនទីបង្ហាញផ្លូវ និងផែនការសកម្មភាពលម្អិត ដែលបានកំណត់
- វិភាគបញ្ហាប្រឈម និងស្នើសុំដំណោះស្រាយជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពាក់ព័ន្ធនឹងការអនុវត្តការរាយការណ៍ព័ត៌មានចីរភាព តាមវិស័យនៅកម្ពុជា
- រៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆមាស និងប្រចាំឆ្នាំ ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អនុវត្តមុខងារភារកិច្ចផ្សេងទៀត តាមការប្រគល់ជូនពី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ៥.-**

**គ.រ.ច.** មានលេខាធិការដ្ឋានមួយ ជាសេនាធិការរដ្ឋបាល និងបច្ចេកទេស។ លេខាធិការដ្ឋាននៃ **គ.រ.ច.** ដឹកនាំដោយប្រធាន១រូប អនុប្រធាន១រូប និងមានមន្ត្រីមួយចំនួនតាមការចាំបាច់ ដែលត្រូវតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់តួនាទីភារកិច្ចដោយសេចក្តីសម្រេចរបស់ប្រធាន **គ.រ.ច.**។

លេខាធិការដ្ឋាននៃ **គ.រ.ច.** មានមុខងារភារកិច្ចដូចតទៅ៖

- រៀបចំសេចក្តីព្រាងផែនការ គោលការណ៍ និងវិធានការ ពាក់ព័ន្ធទៅនឹងការរាយការណ៍ព័ត៌មានចីរភាពដើម្បីដាក់ជូន **គ.រ.ច.**
- រៀបចំសេចក្តីព្រាងផែនទីបង្ហាញផ្លូវសម្រាប់ការអនុវត្តការរាយការណ៍ព័ត៌មានចីរភាព ដើម្បីដាក់ជូន **គ.រ.ច.**
- សិក្សា ស្រាវជ្រាវ តាមដានបច្ចុប្បន្នភាព និងឧត្តមានុវត្តន៍ជាអន្តរជាតិពាក់ព័ន្ធការរាយការណ៍ព័ត៌មានចីរភាព
- រៀបចំកិច្ចប្រជុំ និងរបាយការណ៍កិច្ចប្រជុំរបស់ **គ.រ.ច.**
- ប្រមូល ចងក្រងនិងផ្សព្វផ្សាយ ទិន្នន័យ អំពីការរាយការណ៍ព័ត៌មានចីរភាពនានា
- រៀបចំសេចក្តីព្រាងរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំ ដើម្បីដាក់ជូន **គ.រ.ច.**
- បំពេញមុខងារភារកិច្ចដែលពាក់ព័ន្ធផ្សេងទៀត តាមការប្រគល់ជូនពីប្រធាន **គ.រ.ច.**។

**ប្រការ៦.-**

ប្រធាន **គ.រ.ច.** កោះប្រជុំនិងជាអធិបតីនៃអង្គប្រជុំរបស់ **គ.រ.ច.**។ អនុប្រធាន និងសមាជិក **គ.រ.ច.** ត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធាន។ ប្រធាន **គ.រ.ច.** អាចប្រគល់សិទ្ធិជូនអនុប្រធានឱ្យកោះប្រជុំ និងដឹកនាំកិច្ចប្រជុំរបស់ **គ.រ.ច.** បាន។ លិខិតអញ្ជើញ របៀបវារៈ និងឯកសារពាក់ព័ន្ធ ត្រូវផ្ញើជូនសមាសភាពដែលនឹងត្រូវអញ្ជើញឱ្យចូលរួមប្រជុំយ៉ាងតិច១០(ដប់)ថ្ងៃនៃថ្ងៃធ្វើការ មុនកាលបរិច្ឆេទប្រជុំ វៀរលែងតែរបៀបវារៈប្រជុំមានភាពបន្ទាន់។

ករណីប្រធាន **គ.រ.ច.** អវត្តមានដោយប្រការណាមួយ ប្រធាន **គ.រ.ច.** ត្រូវផ្ទេរសិទ្ធិជូនអនុប្រធានឱ្យដឹកនាំកិច្ចប្រជុំជំនួស ដើម្បីធានានិរន្តរភាព និងប្រក្រតីភាពនៃការអនុវត្តមុខងារភារកិច្ចរបស់ **គ.រ.ច.** ។

**ប្រការ៧.-**

កិច្ចប្រជុំរបស់ **គ.រ.ច.** អាចប្រព្រឹត្តទៅបាន លុះត្រាតែមានវត្តមានសមាជិកលើសពីពាក់កណ្តាលនៃសមាជិកទាំងអស់។ ក្នុងករណីខ្វះកូរ៉ុម ប្រធានអង្គប្រជុំត្រូវកោះអញ្ជើញប្រជុំម្តងទៀតជាលើកទីពីរ ក្នុងរយៈពេលយ៉ាងតិច៥(ប្រាំ)ថ្ងៃ ក្រោយកាលបរិច្ឆេទដែលបានកំណត់លើកដំបូង។ ការប្រជុំលើកទីពីរនេះ មិនតម្រូវឱ្យមានសមាជិកគ្រប់ចំនួនកូរ៉ុមឡើយ ហើយត្រូវពិភាក្សាតែលើរបៀបវារៈដែលខកខានប្រជុំពីលើកមុនប៉ុណ្ណោះ។

ការអនុម័តរបស់ **គ.រ.ច.** ត្រូវយកតាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកដែលមានវត្តមាន និងធ្វើឡើងដោយចំហរតាមវិធីលើកដៃ។ ករណីចំនួនសំឡេងស្មើគ្នាក្នុងការអនុម័តលើបញ្ហាណាមួយ សំឡេងរបស់ប្រធានអង្គប្រជុំមានឧត្តមានុភាព។ នៅក្នុងការអនុម័តរបស់ **គ.រ.ច.** មិនត្រូវមានសម្លេងអនុប្បវាទឡើយ។ ប្រសិនបើមិនអាចរកសំឡេងអនុម័តបានតាមការកំណត់ក្នុងវាក្យខណ្ឌទី១ និងទី២ នៃកថាខណ្ឌនេះ **គ.រ.ច.** ត្រូវធ្វើការអនុម័តជាលើកទី២ ដោយយកតាមមតិភាគច្រើនដោយប្រៀបនៃចំនួនសមាជិកដែលមានវត្តមាន។

នៅក្នុងដំណើរការប្រជុំ សមាជិកដែលមានបំណងបញ្ចេញយោបល់ត្រូវលើកដៃ ហើយប្រធានអង្គប្រជុំជាអ្នកសម្របសម្រួលផ្តល់ពេលវេលាសមស្របដល់វាគ្មិនតាមលំដាប់មុនក្រោយ និងមិនលើសពីសារៈសំខាន់ដែលត្រូវបញ្ចេញយោបល់ព្រមទាំងមិនប្រាសចាកប្រធានបទឬរបៀបវារៈ។

**ប្រការ៨.-**

ធនធាន និងថវិកាសម្រាប់ចំណាយលើកិច្ចដំណើរការរបស់ **គ.រ.ច.** ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់កញ្ចប់ថវិការបស់និយ័តករគណនេយ្យនិងសវនកម្ម។ ប្រធាន អនុប្រធាន និងសមាជិក **គ.រ.ច.** និងប្រធាន អនុប្រធាន និងសមាជិកលេខាធិការដ្ឋាននៃ **គ.រ.ច.** ត្រូវទទួលបានប្រាក់លាភការដែលនឹងត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៩.-**

អគ្គលេខាធិការនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម ស្ថាប័នពាក់ព័ន្ធដូចមានចែងក្នុងប្រការ១ ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និងគ្រប់បុគ្គលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១៣កើត ខែ ពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ ឧសភា គ.ស.២០២៥

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់អង្គភាពនិងសមាសភាពពាក់ព័ន្ធ
- ដូចប្រការ៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ